

**មេធាវីរដ្ឋអាជ្ញាតំបន់មីដ្ឋលសេក្ស៍**

Gerry Leone

កូនក្មេងគឺជាអាទិភាពដែលមានតំលៃ និងគួរឲ្យយកចិត្តទុកដាក់ជាទីបំផុតរបស់យើង។ ពួកគេក៏ងាយនឹងទទួលរងនូវភាពឈឺចាប់បំផុតក្នុងចំណោមយើងទាំងអស់គ្នាដែរ។ គ្មាននរណាម្នាក់ចង់ជឿថា មានគេចេតនាធ្វើឲ្យកូនរបស់យើងទទួលរងគ្រោះនោះទេ។ ជាអកុសល ការធ្វើបាបកើតឡើងភាគច្រើននៅក្នុងក្រុមគ្រួសាររបស់ក្មេងផ្ទាល់តែម្តង។ ភស្តុតាងដែលគេបានប្រមែប្រមូលតាមរយៈការស៊ើបអង្កេត និងដំណើរការកាត់សេចក្តីបានបង្ហាញឲ្យឃើញថា នៅក្នុងសហរដ្ឋអាមេរិកនេះមានក្មេងដល់ទៅមួយលាននាក់ក្នុងមួយឆ្នាំត្រូវបានគេធ្វើបាប និងគ្មានការយកចិត្តទុកដាក់។ ផ្ទុយទៅវិញ គេមិនអាចសន្និដ្ឋានបាននូវចំនួនករណីជាច្រើនដែលមិនត្រូវបានគេរាយការណ៍ឡើយ។

បទបញ្ញត្តិលើអ្នករាយការណ៍តាមច្បាប់ទូទៅរបស់រដ្ឋម៉ាស្សាជូសេត្ស៍មាត្រការទី១១៩ ជំពូកទី៥១A តំរូវឲ្យអ្នកជំនាញការកាន់សំណុំរឿងដែលមាននាទីធ្វើការជាមួយក្មេង រាយការណ៍ទៅក្រសួងកុមារនិងគ្រួសារ (DCF) រដ្ឋម៉ាស្សាជូសេត្ស៍ បើសិនជាគេមានការសង្ស័យលើការធ្វើបាប និងមិនយកចិត្តទុកដាក់លើក្មេងដែលមានអាយុក្រោយ ១៨ឆ្នាំ។

វាជាការសំ ខាន់ដែលអ្នករាយការណ៍ក្រោមបទបញ្ញត្តិយល់ពីភាពទទួលខុសត្រូវរបស់ពួកគេ។ សៀវភៅស្តើងនេះត្រូវបានរៀបចំឡើងដើម្បីជួយលោក-អ្នកឲ្យយល់ពីច្បាប់នៃការរាយការណ៍ពីការរំលោភបំពានលើក្មេង ហើយក៏ជាមគ្គុទ្ទេសក៏ក្នុងការបំពេញរបាយការណ៍ជំពូកទី ៥១A។

លើសពីនេះទៀត មានបុគ្គលិកម្នាក់នៅចាំជួយបាននៅឯអង្គភាពការបំពានលើក្មេងនៅការិយាការពារគ្រួសាររបស់យើង ដើម្បីជួយលោក-អ្នកទាក់ទងទៅនឹងសំណួរ និងក្តីកង្វល់ផ្សេងៗ។ អង្គភាពនេះដោះស្រាយនូវបញ្ហាធ្វើបាបបំពានផ្នែកផ្លូវភេទ និងសពាង្គកាយដ៏ធ្ងន់ធ្ងរលើក្មេងនៅក្រោមអាយុ១៦ឆ្នាំ ក៏ដូចជាករណីពាក់ព័ន្ធការកេងយកផលប្រយោជន៍ពីក្មេងដែលមានវ័យក្រោម ១៨ឆ្នាំដែរ។

ការធ្វើការរួមគ្នាយើងពិតជាអាចធ្វើបានល្អបំផុតក្នុងការធានានូវសុវត្ថិភាព និងសុខុមាលភាពរបស់ក្មេងគ្រប់រូបក្នុងការមើលខុសត្រូវរបស់យើង ។

## ពាក្យសព្ទដែលលោក-អ្នកគួរតែដឹង

**អ្នកបីបាច់ថែរក្សា** រួមបញ្ចូលទាំងមាតាបិតារបស់ក្មេង ឪពុកម្តាយចុង អាណាព្យាបាល ជីដូនជីតា គ្រូបង្រៀន អ្នកមើលក្មេង គ្រូកីឡា អ្នកបើករថយន្តបឺស អ្នកផ្តល់ដំបូន្មានពេលបោះជំរំ ហើយនិងអ្នកដទៃទៀតដែលគេទុកចិត្តឲ្យទទួលខុសត្រូវលើផ្នែកសុខភាព និងសុខុមាលភាពរបស់ក្មេង។ ពាក្យសព្ទមានអត្ថន័យត្រូវគេបកស្រាយយ៉ាងទូលំទូលាយ ហើយរួមទាំងអ្នកមើលថែទាំដែលជាអនីតិជនផង។

**ការរំលោភបំពាន:** សកម្មភាពណាមួយដែលប្រព្រឹត្តឡើងដោយមិនមែនចៃដន្យដោយអ្នកមើលបីបាច់ថែរក្សាក្មេង ដែលបណ្តាល ឬក៏បង្កើតឲ្យមានរបួសគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយ ឬសតិអារម្មណ៍ ឬកការប្រព្រឹត្តនៃអំពើបំពានផ្នែកផ្លូវភេទទៅលើក្មេង ដូចដែលបានចែងក្នុងនិតិបទឧក្រិដ្ឋរបស់ រដ្ឋ ឬក៏ការប៉ះពាល់ខាងផ្លូវភេទរវាងអ្នកបីបាច់ថែរក្សានិងកុមារ។

**ការមិនយកចិត្តទុកដាក់:** ភាពបរាជ័យរបស់អ្នកមើលថែរក្សា ទាំងដោយចេតនា ឬដោយការធ្វេសប្រហែស ឬក៏អសមត្ថភាព ក្នុងការចាត់វិធានការណ៍ជាចាំបាច់ចំពោះការផ្តល់ឲ្យក្មេងនូវម្ហូបអាហារគ្រប់គ្រាន់ជាអប្បបរិមា សំលៀកបំពាក់ ទីជំរក ការថែទាំខាងវេជ្ជសាស្ត្រ ការមើលខុសត្រូវ ភាពនឹងនខាងសតិអារម្មណ៍ និងលូតលាស់ ឬក៏ការបីបាច់ថែរក្សាដែលចាបាច់ដទៃទៀត។ ផ្ទុយទៅវិញ ភាពអសមតឬភាពបែបនេះ មិនអាចសំអាងលើប្រភពធនធានសេដ្ឋកិច្ចមិនគ្រប់គ្រាន់តែមួយមុខ ឬក៏សំអាងតែមួយមុខលើលក្ខខណៈពិការភាពដែលមាននោះឡើយ។

**របួសផ្នែករាងកាយ:** មរណៈភាព បាក់បែកឆ្អឹង ឈាមកកក្នុងទងខួរក្បាល រលាក ភាពពិការនៃសរីរាង្គណាមួយ ឬក៏របួសមិនតូចតាចបែបនេះ, ការហើមជាលិកាទន់ៗ ឬក៏ការជាំស្បែកអាស្រ័យតាមវ័យរបស់ក្មេង, កាលៈទេសៈក្នុងពេលដែលរបួសនោះកើតឡើង ហើយនិងទីកន្លែងនិងចំនួនស្នាមជាំទាំងនោះ, ការញៀនថ្នាំតាំងពីកំណើត ហើយខកខានមិនបានលូតលាស់។ សកម្មភាពនៃការអង្រន់កូនង៉ាត្រូវគេចាត់ទុកថាជាការបំពានផ្នែករាងកាយខណៈដែលរបួសឆ្អឹងខ្នង ក្បាល ហើយនិងក កើតឡើងជាញឹកញាប់បណ្តាលពីការអង្រន់យោគកូនក្មេងយ៉ាងសាហាវយង់ឃ្នង។

**របួសផ្នែកសតិអារម្មណ៍:** ភាពពិការ ឬភាពមិនលូតលាស់ធម្មតាខាងគំនិតបញ្ញា ឬក៏សមត្ថភាពផ្លូវចិត្តរបស់កុមារ ដូចដែលបានសង្កេតមើលដោយការថយចុះគួរឲ្យកត់សំគាល់ និងយ៉ាងសន្ធឹកតាមសមត្ថភាពកុមារក្នុងការប្រព្រឹត្តធម្មតាមទំហំការអនុវត្តន៍ និងអាកប្បកិរិយា។

## ការទាក់ទងទៅក្រសួងកុមារនិងក្រុមគ្រួសារ (DCF)

បេសកកម្មរបស់DCF គឺដើម្បីការពារកុមារដែលត្រូវបានគេរំលោភធ្វើបាប ឬមិនមានការយកចិត្តទុកដាក់ពីអ្នកបីបាច់ថែរក្សា ហើយដើម្បីធានាថា កុមារម្នាក់ៗ មានសុវត្ថិភាព ការចិញ្ចឹមបីបាច់ និងផ្ទះនៅជាអចិន្ត្រៃយ៍។ DCF ផ្តល់សេវាកម្មការពារជាច្រើនដើម្បីជួយគាំទ្រ និងការពង្រឹងក្រុម គ្រួសារដែលមានក្មេងជួបនឹងគ្រោះថ្នាក់នៃការរំលោភធ្វើបាប ឬការមិនយកចិត្តទុកដាក់។ មានការិយាល័យ DCF ប្រចាំតំបន់ចំនួន ៦ ដែលផ្តល់កិច្ចបំរើការនៅក្នុងទីក្រុងនានាក្នុងតំបន់មីដ្ឋលសេក្ស៍ (Middlesex County)។ សំរាប់ការពីគ្រោះយោបល់លើករណីណាមួយ ឬសំណុំឯកសាររបាយ ការណ៍ ៥១A លោក-អ្នកគួរតែទូរស័ព្ទទៅការិយាល័យដែលបំរើការក្នុងទីក្រុងដែលក្មេងរស់នៅ។



**ទូរស័ព្ទបន្ទាន់ពាក់ព័ន្ធនឹងគ្រោះថ្នាក់កុមាររបស់ DCF**
**1-800-792-5200**
***បន្ទាប់ពីម៉ោង ៥:០០ល្ងាច និងចុងសប្តាហ៍***

**ការិយាល័យនៅតំបន ARLINGTON** **781 641-8500**

បំរើ Arlington, Belmont, Lexington, Newton, Waltham, Watertown, Weston

**ការិយាល័យ CAMBRIDGE** **617 520-8700**

បំរើ Burlington, Cambridge, Somerville, Wilmington, Winchester, Woburn

**ការិយាល័យ FRAMINGHAM** **508 424-0100**

បំរើActon, Ashland, Bedford, Boxborough, Carlisle, Concord, Framingham, Holliston, Hopkinton, Hudson, Lincoln, Littleton, Marlborough, Maynard, Natick, Sherborn, Stow, Sudbury, Wayland

**ការិយាល័យ LOWELL** **978 275-6800**

បំរើ Billerica, Chelmsford, Dracut, Dunstable, Lowell, Tewksbury, Tyngsboro, Westford

**ការិយាល័យ MALDEN** **781 388-7100**

បំរើ Everett, Malden, Medford, Melrose, North Reading, Reading, Stoneham, Wakefield

**ការិយាល័យ NORTH CENTRAL** **978 466-1500**

បំរើ Ashby, Ayer, Groton, Pepperell, Shirley, Townsend

# ការធ្វើបាបនិងមិនយកចិត្តទុកដាក់ចំពោះក្មេង

## *អ្វីដែលអ្នករាយការណ៍តាមបទបញ្ញត្តិត្រូវដឹង*

### តើច្បាប់អ្នករាយការណ៍តាមបទបញ្ញត្តិជាអ្វី?

ជំពូក ១១៩ មាត្រា ៥១A នៃច្បាប់ទូទៅ
របស់រដ្ឋម៉ាសូជូសេត្ស៍តំរូវឲ្យអ្នកជំនាញការ ទាំងឡាយណាដែលការ-
ងាររបស់គេមានការ ប្រាស្រ័យទាក់ទងជាមួយមនុស្សវ័យក្មេង ត្រូវ
ជូនដំណឹងទៅក្រសួងកុមារ និងក្រុមគ្រួសារ (DCF) នៅ-
ពលដែលគេសង្ស័យថាមានការ បំពានធ្វើបាប ឬមិនយកចិត្តទុកដាក់ចំពោះ
ក្មេងដែលមានអាយុក្រោមអាយុ១៨ឆ្នាំ។ អ្នក រាយការណ៍តាមបទបញ្ញត្តិរួមមាន
វេជ្ជបណ្ឌិត អ្នកអប់រំ អាចារ្យ អ្នកផ្តល់ដំបូលទ្ធាន អ្នក កាន់សំណុំរឿងក្មេង
ឪពុកម្តាយចិញ្ចឹម ប៉ូ លីស អ្នកពន្លត់ភ្លើង និងបុគ្គលិកអាជ្ញា អង្កេត។
លើសពីការបើកសំណុំរឿងនៅឯDCF លោក-អ្នកក៏អាចជូនដំណឹងទៅប៉ូលីស
អាជ្ញាធរក្រុង ឬក៏ការិយាល័យអ្នកគាំទ្រការ ពារក្មេង។

### តើវាមានបញ្ហាដែរឬអត់ បើសិនជាជន សង្ស័យថាបានប្រព្រឹត្តិជាអ្នកមើលក្មេង?

DCF គឺជាស្ថាប័នទទួលរាយការណ៍ទាំងអស់ពី ការសង្ស័យលើការបំពានធ្វើបាប
និងមិនយក ចិត្តទុកដាក់ចំពោះកុមារដែលមានវ័យក្រោម ១៨ឆ្នាំ
នៅក្នុងរដ្ឋម៉ាសូជូសេត្ស៍។ DCF ស៊ើប-
អង្កេតលើករណីរបាយការណ៍ពីការបំពាន ធ្វើបាប ឬមិនយកចិត្តទុក-
ដាក់ដោយមនុស្ស ចាស់ ឬក៏អនីតិជនដែលមាននាទីជាអ្នកមើល
ថែរក្សាក្មេង។ សូម្បីតែក្នុងករណីធ្វើបាបដែល
"មិនមែនជាអ្នកបីបាច់ថែរក្សា" (ដែលអាចរួម បញ្ចូលទាំងការបំពានផ្នែកសពា
ង្គកាយ និង ខាងផ្លូវភេទ ដោយអ្នកក្រៅ អំពើហឹង្សាពេល
យុវវ័យណាត់ជួបខាងក្រៅ និងការរំលោភ បៃ-
បសេពសន្ថវៈលើក្មេងស្រីមិនគ្រប់អាយុ) លោក-អ្នកត្រូវតែបំពេញរបារណ៏
៥១A។

### តើខ្ញុំត្រូវធ្វើរបាយការណ៍ដោយវិធីណា ហើយ តើឆាប់ប៉ុណ្ណាដែរ?

លោក-អ្នកត្រូវទូរស័ព្ទទៅDCF ជាបន្ទាន់ ហើ-
យរាយការណ៍ជាលាយលក្ខណ៏អក្សក្នុង រយៈពេល ៤៨ម៉ោង។
របាយការណ៍គួរតែរួម បញ្ចូលឈ្មោះរបស់លោក-អ្នក ឈ្មោះរបស់ក្មេង
របស់ឪពុកម្តាយក្មេង ឬអាណាព្យាបាល អាយុ និងភេទរបស់ក្មេង
ធម្មជាតិនិងទំហំនៃរបួសលើ ក្មេង ការបំពានធ្វើបាប ឬភាពមិនយកចិត្តទុក
ដាក់ និងស្ថានភាពដែលលោក-អ្នកចាប់ផ្តើមដឹង ពីរបួសនោះ, បើសិនជា-
មាន, តើសកម្មភាព អ្វីខ្លះត្រូវបានធ្វើដើម្បីជួយសង្គ្រោះក្មេងនោះ។ ភិន-
ភាគជនសង្ស័យថាបានប្រព្រឹត្ត ហើយនិងព៏ត មានដទៃទៀតដែលលោក-
អ្នកគិតថា វាអាច មានប្រយោជន៏ដល់ការពន្យល់ពីគ្រោះថ្នាក់នោះ។

### តើមានអ្វីកើតឡើងក្រោយពី ឌជឈ បានទទួល របាយការណ៍របស់ខ្ញុំ?

- DCF ត្រូវសំរេច ថាតើត្រូវ "រើសយក" សំ ណុំរឿ
ងសំរាប់ការស៊ើបអង្កេតឬអត់។ DCF នឹង "រើសចោល" សំណុំរឿ
ងណាដែលការ ចោទប្រកាន់មិនគ្រប់លក្ខណៈចំពោះការបំពានធ្វើបាប
ឬមិនយកចិត្តទុកដាក់ ឬក៏ វាមិនប្រាកដ ថាតើជនសង្ស័យថាបានប្រ
ព្រឹត្តនោះជាអ្នកបីបាច់ថែរក្សាឬអត់។ សំណុំ រឿ
ងជាច្រើនដែល "រើសចោល" នឹងត្រូវណែ នាំទៅប៉ូលីសក្នុងក្រុង
និងមេធាវីរដ្ឋអាជ្ញា ដើម្បីធ្វើការស៊ើបអង្កេតនិងផ្តន្ទាទោស។
- DCF ស៊ើបអង្កេតពីរបាយការណ៍ណាដែល
អ្នកបីបាច់ថែរក្សាមានការបំពានធ្វើបាប ឬ មិនយកចិត្តទុកដាក់។
ក្នុងករណីបន្ទាន់ ការស៊ើប-
អង្កេតត្រូវតែថ្លឹងថ្លែងលើសុវត្ថិភាពនិងអាណាព្យាបាលរបស់ក្មេងក្នុងរយៈពេល
២៤ម៉ោង ហើយត្រូវដាក់ជូនរបាយការណ៍
ច្បាប់ចុងក្រោយបំផុតក្នុងរយៈពេល ៥ថ្ងៃ។ ការស៊ើប-
អង្កេតករណីមិនបន្ទាន់ត្រូវបញ្ចប់ ក្នុងរយៈពេល ១៥ថ្ងៃ។
- DCF នឹង "គាំទ្រ" របាយការណ៍ក្រោយការ ស៊ើបអង្កេត បើសិនជា-
មានហេតុផលសម រម្យដែលអាចជឿថា អ្នកបីបាច់ថែរក្សាបាន
បំពានធ្វើបាប ឬមិនយកចិត្តទុកដាក់លើ ក្មេង។ DCF
នឹង "មិនគាំទ្រ" របាយការណ៍ ឡើយ បើសិនជាភស្តុតាងនោះបង្ហាញថា
ក្មេងនោះមិនត្រូវបានគេធ្វើបាបដោយជនដែដល់ ឬក៏ដោយអ្នកបីបាច់ថែរក្សា។
DCF នឹងផ្តល់សេវាកម្មទៅក្រុមគ្រួសារនៅ ពេលណាដែលសមរម្យ។
- DCF នឹងឲ្យដំណឹងទៅប៉ូលីសក្នុងក្រុង និ-
ងរដ្ឋអាជ្ញាស្រុកជាបន្ទាន់នូវរបាយការណ៍ណាដែលគេដាក់មក និងបញ្ជូន
ច្បាប់ចម្លងទាំងអស់ដែលបញ្ជាក់ពីរបាយការណ៍ ៥១A ដោយមិនគិតពីកំ
ណត់ហេតុពីមុន នៅពេលបញ្ចប់ការ ស៊ើបអង្កេត។

### តើខ្ញុំអាចត្រូវគេដាក់ទោសដោយវិធីណាទេក្នុងការបំពេញរបាយការណ៍លេខ ៥១A?

បើសិនជាលោក-អ្នកដាក់របាយការណ៍ក្នុង បំណងល្អ ឧទាហរណ៍ដូចជាលោក-
អ្នកជឿ ថា របាយការណ៍នោះវាពិតប្រាកដ និង ទៀងត្រង់ ដែលមិន-
អាចមានបណ្តឹងបទរដ្ឋ ប្បវេណី ឬព្រហ្មទណ្ឌប្តឹងប្រឆាំងនឹងលោក អ្នកបាន
ក្នុងការបំពេញកាតព្វកិច្ចជាអ្នក រាយការណ៍តាមបទបញ្ញត្តិតម្រូវ។

### តើខ្ញុំអាចត្រូវគេដាក់ទោសដោយសារមិន បានធ្វើរបាយការណ៍លេខ ៥១A ឬទេ?

បើសិនជាលោក-អ្នកមិនបានធ្វើរបាយ ការណ៍នៅពេលគេតំរូវឲ្យធ្វើ លោក-អ្នក
អាចត្រូវគេប្តឹង និងពិន័យដល់ទៅ ១០០០ ដុល្លា បើគេរកឃើញថាធ្វើខុស។
ចាប់ពី ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១០ ទៅវាជាបទ ឧក្រិដ្ឋដែល-
អាចដាក់ទោសបានដោយការ ពិន័យ ឬជាប់ពន្ធាធាគារដល់បុគ្គលណា
ម្នាក់ដែលដាក់របាយការណ៍ឥតប្រយោជន៏
និងដល់ជាអ្នករាយការណ៍តាមបទបញ្ញត្តិ ណាដែលមានចេតនាខកខាន-
មិនបានដាក់ របាយការណ៍នៅពេលដែលគេដឹងថា មាន ការធ្វើបាប
ឬក៏មិនយកចិត្តទុកទៅលើក្មេង ដែលបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរដល់រាង កាយ
ឬដល់បាត់បង់ជីវិតក្មេងនោះ។

### តើខ្ញុំអាចផ្ទេរនាទីរាយការណ៍នេះទៅចៅ ហ្វាយនាយបានឬទេ?

សេចក្តីសំរេចកក្នុងការបំពេញសំណុំរឿង មិនអាចផ្ទេរបានទេ។
បើសិនជាលោក-អ្នកជាបុគ្គលិករបស់ស្ថាប័នពេទ្យសាធារណៈ ឬក៏ឯកជន
សាលាឬក៏គ្រូបង្រៀន លោក-អ្នកអាចជំរាបដំណឹងនេះទៅបុគ្គលដែលទទួល
ខុសត្រូវ ឬក៏ភ្នាក់ងាររបស់គេដែលនឹងក្លាយ ជាអ្នកទទួលខុសត្រូវក្នុងការ-
ដាក់របាយ ការណ៍។

# មក្កុទ្ទេសក៏

# ប្រសិទ្ធិភាពរបាយការណ៍ ៥១A



# ការឆ្លើយតបទៅនឹងសេចក្តីរាយការណ៍ការ បំពានធ្វើបាប និងការមិនយកចិត្តទុកដាក់ ទៅលើកុមារ


## មេធាវីរដ្ឋអាជ្ញាតំបន់មីដ្លសេក្ស៍

GERRY LEONE

**អង្គភាពការពារកុមារពីការរំលោភធ្វើបាប**

THE CHILD ABUSE UNIT
15 COMMONWEALTH AVENUE
WOBURN, MA 01801
(781) 897-8400
**www.middlesexda.com**


***ដើម្បីរាយការណ៍ពីកុមារដែលរងការរំលោភធ្វើបាប ឬមិនយកចិត្តទុកដាក់ សូមទូរស័ព្ទ***
**Child-At-Risk-Hotline 1-800-792-5200**